ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

អគ្គលេខាធិការដ្ឋាន

# របាយការណ៍សមិទ្ធកម្មប្រចាំត្រីមាសទី ១ ឆ្នាំ ២០១៨

## កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

### ក. របាយការណ៍លម្អិត

| គោលបំណង/ចង្កោមសកម្មភាព | សូចនាករសមិទ្ធកម្មគន្លឹះ ប្រចាំត្រីមាសទី ១ | វឌ្ឍនភាពសម្រេចបាន (ជាអក្សរ) | វឌ្ឍនភាពសម្រេចបាន ធៀបសូចនាករ (ជា %) | បញ្ហាប្រឈម | សំណូមពរ |
|---|---|---|---|---|---|
| ផ្នែកទី ១÷បន្តពង្រឹងភាពជឿទុកចិត្តនៃថវិកា | | | | | |
| ១១. បន្តពង្រឹងការគ្រប់ គ្រងចំណូលនិងការអនុវត្តផែនការប្រមូលចំណូល | ការប្រមូលចំណូលត្រូវបានបង្កើនយ៉ាងហោចណាស់ ០,៥ពិន្ទុភាគរយនៃ ផសស ប្រចាំឆ្នាំ | | | | |
| ១១.២. បន្តកែលម្អគោលនយោបាយ និងរដ្ឋបាលគយ, ពន្ធដារ និងចំណូលមិនមែនសារពើពន្ធ | ១. ស្តង់ដារសេវានៃការបង់ និងប្រមូលចំណូល ត្រូវបានកែលម្អ និងអនុវត្ត<br>២. យន្តការផ្តល់សេវាបង់ចំណូល (បញ្ជរពិគ្រោះយោបល់) ត្រូវបានពង្រឹង | | | | |
| ១១.២.១ ពង្រឹងនិងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងនិងការអនុវត្តរជ្ជទេយ្យចំណូលអនុលោមតាមថវិកាកម្មវិធីរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | -ផែនការរជ្ជទេយ្យចំណូលរបស់គសហវ ត្រូវបានសម្របសម្រួល បូកសរុប និងកែលម្អ<br>-របាយការណ៍ប្រចាំត្រីមាស<br>ទី១ ស្តីពីការអនុវត្តរជ្ជទេយ្យចំណូលរបស់គសហវ ត្រូវបានសម្របសម្រួល តាមដាន បូកសរុប និងវាយតម្លៃពីប្រសិទ្ធភាព [illegible] | -បានរៀបចំសេចក្តីព្រាងលិខិតស្នើសុំផែនការរជ្ជទេយ្យចំណូលពីគ្រប់អង្គភាពថវិកាពាក់ព័ន្ធ<br>-បានរៀបចំតារាង Excel ដើម្បីគ្រប់គ្រងផែនការរជ្ជទេយ្យ ចំណូល និងការអនុវត្តរជ្ជទេយ្យចំណូលរបស់ គសហវ | ៣០.០០% | អង្គភាពថវិកា មួយចំនួនមានចំណូលរជ្ជទេយ្យប៉ុន្តែពុំមានផែនការច្បាស់លាស់ គឺអនុវត្តតាមចំណូលជាក់ស្តែង | |
| ១៤. កែលម្អការអនុវត្តថវិកា និងពង្រឹងការអនុវត្តផែនការចំណាយ | | | | | |

| | | | | | |
|---|---|---|---|---|---|
| ១៤.២. ពង្រឹងការរៀបចំ និងអនុវត្តផែនការ ចំណាយឱ្យមានសុក្រឹត្យភាព | ១.ការអនុវត្តថវិកាធៀបផែនការចំណាយ មានកម្រិតលម្អៀង +/-៥% | | | | |
| ១៤.២.១ រៀបចំ ត្រួតពិនិត្យ វាយតម្លៃ និងកែលម្អលើទម្រង់កម្មវិធីចំណូល-ចំណាយផ្ទៃក្នុង កសហវ អនុលោមតាមថវិកាកម្មវិធី | ទម្រង់កម្មវិធីចំណូល-ចំណាយដែលបានដាក់ចេញត្រូវបានត្រួតពិនិត្យ និងវាយតម្លៃ ដើម្បីកែលម្អបន្ថែម | បានសិក្សាពីចំណុចខ្វះខាត នៃទម្រង់កម្មវិធីចំណូល-ចំណាយដែលបានរៀបចំកន្លងមក ដើម្បីធ្វើការកែលម្អបន្ថែម | ១០០.០០% | | |
| **ផ្នែកទី ២៖ បន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ** | | | | | |
| ២៣. ពង្រឹងការអនុវត្តប្រព័ន្ធគណនេយ្យថ្មី ប្រព័ន្ធកត់ត្រាថ្មី ប្រព័ន្ធរបាយការណ៍ថ្មី | | | | | |
| ២៣.៣. ដាក់ឱ្យអនុវត្តយន្តការដើម្បីបញ្ចប់ការចុះបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ និងធ្វើបច្ចុប្បន្នភាពជាប្រចាំ | ១. លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ត្រូវបានបញ្ចប់<br>២. ប្រព័ន្ធគ្រប់គ្រងទិន្នន័យបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ត្រូវបានបញ្ចប់ | | | | |
| ២៣.៣.១. ពង្រឹងការកត់ត្រា តាមដាន និងការចុះបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់កសហវក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យបញ្ជីសារពើភណ្ឌ និង ធ្វើបច្ចុប្បន្នភាពជាប្រចាំ | ប្រព័ន្ធគ្រប់គ្រងទិន្នន័យបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋត្រូវបានប្រើប្រាស់ និងបញ្ចូលទិន្នន័យសាកល្បង | បានបញ្ចូលសាកល្បងទិន្នន័យទ្រព្យសម្បត្តិរដ្ឋរបស់អង្គភាពប្រើប្រាស់ចំនួន ០៣ គឺអគ្គ-លេខាធិការដ្ឋានកសហវ.<br>អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងអគ្គនាយកដ្ឋានពន្ធដារ ក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់កសហវ. | ១០០.០០% | | |
| **ផ្នែកទី ៣៖ ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ** | | | | | |
| ៣១. ពង្រឹង និងពង្រីកការអនុវត្តថវិកាកម្មវិធី និង ការត្រួតពិនិត្យថវិកា | ថវិកាកម្មវិធីត្រូវបានអនុវត្ត ប្រកបដោយប្រសិទ្ធភាព | | | | |
| ៣១.១. ពិនិត្យឡើងវិញ និងកែលម្អការអនុវត្តថវិកាកម្មវិធីទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ | ១.របាយការណ៍ស្តីពីការពិនិត្យឡើងវិញ និងការកែលម្អ ត្រូវបានរៀបចំ ដោយរំលេចឱ្យឃើញពី របកគំហើញ និងអនុសាសន៍នានានិងដាក់ឱ្យអនុវត្ត | | | | |
| ៣១.១.១. រៀបចំបង្កើតប្រព័ន្ធ Database សម្រាប់គ្រប់គ្រងការអនុវត្តសន្និធិឥណទានថវិការបស់កសហវ | ប្រព័ន្ធ Database សម្រាប់គ្រប់គ្រងការអនុវត្តសន្និធិឥណទានថវិការបស់កសហវ ត្រូវបានដាក់ឱ្យប្រើប្រាស់សាកល្បង | បានដាក់ឱ្យប្រើប្រាស់សាកល្បងប្រព័ន្ធ Database សម្រាប់គ្រប់គ្រងការអនុវត្តសន្និធិឥណទានថវិការបស់កសហវ. ដើម្បីតាមដានសន្និធិឥណទានរបស់អង្គភាពថវិកានៃកសហវ. | ១០០.០០% | | |

| | | | | | |
|---|---|---|---|---|---|
| ៣១.៤.ត្រួតពិនិត្យឡើងវិញ លើការអនុវត្តសិទ្ធិអំណាចនិងភាពទន់ភ្លន់ដែលបានផ្តល់ជូនអង្គភាពថវិកានិងធ្វើបច្ចុប្បន្នភាព | ១. របាយការណ៍តាមដានការអនុវត្តវិធានការកែលម្អ នៃការអនុវត្តសិទ្ធិអំណាចរបស់អង្គភាពថវិកា ត្រូវបានរៀបចំ(ក្រសួង ស្ថាប័ន)<br>២.គោលការណ៍ណែនាំ ត្រូវបានកែលម្អ និងដាក់ឱ្យអនុវត្ត | | | | |
| ៣១.៤.១.ធ្វើបច្ចុប្បន្នកម្មសេចក្តីណែនាំលេខ ០០៥ សហវ ស្តីពីគោលការណ៍ និងនីតិវិធីផ្ទេរក្នុងសម្រាប់ការអនុវត្តថវិកាកម្មវិធីរបស់កសហវ. | បច្ចុប្បន្នកម្មសេចក្តីណែនាំលេខ ០០៥ ត្រូវបានបញ្ចប់ការរៀបចំសេចក្តីព្រាងកម្រិតអគ្គលេខាធិការដ្ឋាននិងដាក់ជូនថ្នាក់ដឹកនាំបន្តពិគ្រោះយោបល់អន្តរអគ្គនាយកដ្ឋាន | សេចក្តីព្រាងបច្ចុប្បន្នកម្មសេចក្តីណែនាំលេខ ០០៥ត្រូវបានដាក់ប្រជុំជាមួយអគ្គនាយកដ្ឋានពាក់ព័ន្ធចំនួន០១លើក | ១០០.០០% | | |
| **ផ្នែកទី៥÷ការគាំទ្រដល់ការអនុវត្តកម្មវិធីកែទម្រង់ប្រកបដោយជោគជ័យ និងចីរភាព (សមត្ថភាពជំនាញ សមត្ថភាពអនុវត្តកំណែទម្រង់ លើកទឹកចិត្ត)** | | | | | |
| ៥១. បង្កើនភាពជាអ្នកដឹកនាំ, សមត្ថភាព គ្រប់គ្រង និងបណ្តុះឆន្ទៈកំណែទម្រង់ ព្រមទាំង បង្កើនភាពជាម្ចាស់ និងការទទួលខុសត្រូវ ។ | ភាពជាអ្នកដឹកនាំ, សមត្ថភាព គ្រប់គ្រងសមស្រប, ឆន្ទៈ, ភាពជាម្ចាស់ និងការទទួលខុសត្រូវ ត្រូវបានបង្កើនជាបើដាប់ | | | | |
| ៥១.១. ពង្រឹងការអនុវត្តវិធាននិងនីតិវិធីពាក់ព័ន្ធនឹងយន្តការរៀបចំនិងអនុវត្តការងារកែទម្រង់ តាមក្រសួង ស្ថាប័ន និងអង្គភាព តាមសារាចរលេខ ០៩ | វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាព MAP3/GDAP3 សម្រេចបាន ៩០% ជាប្រចាំឆ្នាំ | | | | |
| ៥១.១.១. រៀបចំ និងតាមដានការអនុវត្តផែនការសកម្មភាពរួមដំណាក់កាលទី៣ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់អគ្គលេខាធិការដ្ឋាន | ផែនការសកម្មភាពរួមដំណាក់កាលទី៣ នៃ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់អគ្គលេខាធិការដ្ឋាន ត្រូវបានរៀបចំ និងផ្សព្វផ្សាយ | បានរៀបចំផែនការសកម្មភាពរួមដំណាក់កាលទី៣ នៃ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់អគ្គលេខាធិការដ្ឋាន និងជូនគ្រប់នាយកដ្ឋានផ្សព្វផ្សាយដល់មន្ត្រីក្រោមឱវាទ | ១០០.០០% | | |
| ៥២. បង្កើនប្រសិទ្ធភាពនៃការកសាងសមត្ថភាព និងវិធានការលើកទឹកចិត្ត | | | | | |
| ៥២.១.ពិនិត្យមើលឡើងវិញពីប្រសិទ្ធភាពនិង ស័ក្តិសិទ្ធភាពនៃការបណ្តុះបណ្តាលនិងរៀបចំផែនការកសាងសមត្ថភាពថ្មី | ១ យន្តការវាយតម្លៃប្រសិទ្ធភាពនៃការបណ្តុះបណ្តាលត្រូវបានកែលម្អ<br>២. ផែនការកសាងសមត្ថភាព ត្រូវបានរៀបចំជាប្រចាំត្រីមាស និងប្រចាំឆ្នាំ ប្រកបដោយសមធម៌និងប្រសិទ្ធភាព<br>៣. វគ្គចែករំលែកបទពិសោធន៍ ចំណេះដឹងផ្ទៃក្នុងស្ថាប័ន ត្រូវបានរៀបចំផ្ទេរពីអ្នកបានចូលរួមសិក្ខាសាលា និងវគ្គបណ្តុះ | | | | |

| | | | | | |
|---|---|---|---|---|---|
| ៤២.១.១. រៀបចំយុទ្ធសាស្ត្រគ្រប់គ្រងនិងអភិវឌ្ឍធនធានមនុស្ស២០១៨-២០២៣ | សេចក្តីព្រាងយុទ្ធសាស្ត្រគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានមនុស្ស ត្រូវបានប្រជុំ និង ពិគ្រោះយោបល់កម្រិតអគ្គលេខាធិការដ្ឋាន | សេចក្តីព្រាងយុទ្ធសាស្ត្រគ្រប់គ្រងនិងអភិវឌ្ឍន៍ធនធានមនុស្ស ២០១៨-២០២៣ បានដាក់ប្រជុំពិភាក្សាកម្រិតអគ្គលេខាធិការដ្ឋាន និងបានកែលម្អលើកចុងក្រោយ | ១០០.០០% | | |
| ៤២.១.២. បង្កើតយន្តការត្រួតពិនិត្យ វាយតម្លៃ នៃការអភិវឌ្ឍធនធានមនុស្ស | -គម្រោងតារាងសំណួរសម្រាប់ប្រមូលពត៌មានទាក់ទងនឹងការត្រួតពិនិត្យតាមដានការកសាងសមត្ថភាពមន្ត្រីរាជការកសហវ<br>ត្រូវបានប្រមូលនិងវិភាគ<br>'-សេចក្តីព្រាងឧបករណ៍ នីតិវិធី យន្តការត្រួតពិនិត្យវាយតម្លៃការអភិវឌ្ឍធនធានមនុស្សត្រូវបានដាក់ឆ្លងប្រធានអង្គភាព | -របាយការណ៍ស្តីពីការវិភាគគម្រោងតារាងសំណួរសម្រាប់ប្រមូលពត៌មានទាក់ទងនឹងការ ត្រួតពិនិត្យតាមដានការកសាងសមត្ថភាពមន្ត្រីរាជការកសហវ បានដាក់ជូនថ្នាក់ដឹកនាំ<br>'-សេចក្តីព្រាងកម្មវិធីវាយតម្លៃសមត្ថភាពមន្ត្រី រាជការលើការអនុវត្តប្រកាសលេខ១០៣៣សហវ.ប្រ.ក ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១០ សម្រាប់ឆ្នាំ២០១៥-២០១៨ ត្រូវបានរៀបចំ | ១០០.០០% | | |
| ៤៣. រាជ្រើងការកសាងសមត្ថភាពសម្រាប់អនុវត្ត កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៣ | | | | | |
| ៤៣.១.រៀបចំស្ថាប័នដើម្បីឆ្លើយតបនឹងដំណាក់កាលទី៣ ដោយរួមមាន÷ (១).ការបញ្ចប់វិភាគមុខងារនៅ គ្រប់អគ្គនាយកដ្ឋាននៃកសហវ និងនាយកដ្ឋានរដ្ឋបាល ហិរញ្ញវត្ថុនៃក្រសួង ស្ថាប័ន, (២).រៀបចំ និងអនុវត្តផែនការកែលម្អរចនាសម្ព័ន្ធរបស់អគ្គនាយកដ្ឋាន និងនាយកដ្ឋាននីមួយៗ, (៣). រៀបចំនិង ផ្សព្វផ្សាយ ឯកសារណែនាំស្តីពីប្រព័ន្ធគ្រប់គ្រងថ្មី, (៤).រៀបចំគោលនយោបាយសម្រាប់យុទ្ធសាស្ត្រគ្រប់គ្រងព័ត៌មានវិទ្យានៅ កសហវ, (៥).ការប្រើប្រាស់ជំនួយ បច្ចេកទេសប្រកបដោយប្រសិទ្ធភាព និង (៦). កែ-លម្អការអនុវត្តការងារ តាមរយៈការបង្កើនការប្រើប្រាស់បច្ចេកវិទ្យា | ១. ឯកសារគោលស្តីពីការរៀបចំកម្មវិធីសិក្សាផ្នែកវិភាគថវិកាត្រូវបានរៀបចំរួចរាល់ (បញ្ចាក់÷អនុវត្តឆ្នាំ២០១៨)<br>២.ឯកសារស្តីពីការកសាងសមត្ថ-ភាព មន្ត្រីវិភាគថវិកាត្រូវបានរៀបចំ និងបណ្តុះបណ្តាលមន្ត្រីវិភាគថវិកានៅអគ្គនាយកដ្ឋានថវិកា<br>(បញ្ចាក់÷ អនុវត្តឆ្នាំ២០១៩)<br>៣. បណ្តុះបណ្តាលមន្ត្រីវិភាគថវិកា<br>នៅគ្រប់ក្រសួង ស្ថាប័ន<br>(បញ្ចាក់÷ អនុវត្តឆ្នាំ២០២០)<br>៣.គោលការណ៍ណែនាំសម្រាប់ការវិភាគលើមុខងារ (Job Description) និងលក្ខខណ្ឌយោងការងារ របស់មន្ត្រីក្រុមការងារកែទម្រង់ត្រូវបានធ្វើបច្ចុប្បន្នភាព (ករណីចាំបាច់) | | | | |
| ៤៣.១.១. បង្កើននិងលើកកម្ពស់គុណភាពនិងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈរបស់ច្រកចេញចូលតែមួយរបស់កសហវ | កម្មវិធីសម្រាប់បង្ហាញគម្រងសេវាសាធារណៈរបស់កសហវ តាមរយៈ TV Board ត្រូវបានសិក្សា និងរៀបចំបច្ចេកទេស | បានសិក្សានិងរៀបចំបច្ចេកទេសរួចរាល់ដើម្បីត្រៀមដំឡើង TV Board សម្រាប់បង្ហាញគម្រងសេវាសាធារណៈ | ១០០.០០% | | |
| ៤៣.១.២.រៀបចំទម្រង់បែបបទលក្ខខណ្ឌការងាររបស់មន្ត្រីរាជការនៃកសហវ | ទម្រង់បែបបទនៃលក្ខខណ្ឌការងារថ្មីរបស់មន្ត្រីរាជការត្រូវបានផ្សព្វផ្សាយនិងដាក់ឱ្យអនុវត្ត | ទម្រង់លក្ខខណ្ឌការងារថ្មីត្រូវបានរៀបចំ និងត្រូវផ្សព្វផ្សាយនៅដើមខែមេសា ឆ្នាំ២០១៨ | ៩០.០០% | | |

| | | | | | |
|---|---|---|---|---|---|
| ៥៣.១.៥. រៀបចំឯកសារគោលនយោបាយបច្ចេកវិទ្យាព័ត៌មាន សម្រាប់ កសហវ | គោលនយោបាយបច្ចេកវិទ្យាព័ត៌មានសម្រាប់កសហវ ត្រូវបានធ្វើបច្ចុប្បន្នកម្ម ៣០% ពាក់ព័ន្ធនឹងការប្រើប្រាស់អ៊ីនធើណែតនៅក្នុង កសហវ | សេចក្តីព្រាងសម្រាប់គោលនយោបាយបច្ចេកវិទ្យាព័ត៌មានសម្រាប់ការប្រើប្រាស់អ៊ីនធើណិត បានចងក្រងជិតរួចរាល់ នៅសល់ការសម្រួលខ្លឹមសារ និងផ្ទៀងផ្ទាត់ឡើងវិញ | ១០០.០០% | | |
| ៥៣.១.៨. រៀបចំឱ្យមានមជ្ឈមណ្ឌលទិន្នន័យនិងបណ្តាញបច្ចេកវិទ្យាព័ត៌មាននិងគមនាគមន៍រួម សម្រាប់ កសហវ ដើម្បីទ្រទ្រង់ដល់ការប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យានានាបម្រើដល់វិស័យហិរញ្ញវត្ថុសាធារណៈ | -ផែនការរៀបចំ និងកសាងមជ្ឈមណ្ឌលទិន្នន័យ កសហវ បានធ្វើបច្ចុប្បន្នភាពរួចរាល់<br>-បន្ទប់មជ្ឈមណ្ឌលទិន្នន័យត្រូវកំណត់ទីតាំង និងរៀបចំគ្រោងប្លង់បច្ចេកទេសរួចរាល់ | -មានផែនការ និងតម្រូវការលក្ខណៈបច្ចេកទេសនានា និងមានផែនការសម្រាប់កសាងមជ្ឈមណ្ឌលទិន្នន័យ កសហវ<br>-បានកំណត់ទីតាំងបន្ទប់មជ្ឈមណ្ឌលទិន្នន័យរួចរាល់ គឺនៅជាន់ទី១ អាគារ ខ នៃទីស្តីការ កសហវ និងបានរៀបចំសេចក្តីព្រាងគ្រោងប្លង់បន្ទប់មជ្ឈមណ្ឌលទិន្នន័យរួចរាល់ | ១០០.០០% | | |
| ៥៣.១.៩. បង្កើនប្រសិទ្ធភាព និងពង្រីកវិសាលភាពនៃការផ្តល់សេវាថែទាំ ជួសជុលឧបករណ៍ ប្រឹក្សាយោបល់ និងសេវាផ្សេងៗផ្នែកបច្ចេកវិទ្យាព័ត៌មាននិងគមនាគមន៍នៅក្នុងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ឯកសារតម្រូវការប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រង Help Desk ត្រូវបានរៀបចំរួចរាល់ | ឯកសារតម្រូវការប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រង Help Desk ត្រូវបានព្រាងជិតរួចរាល់ នៅសល់តែការសម្រួលខ្លឹមសារ និងផ្ទៀងផ្ទាត់ឡើងវិញ | ៩៥.០០% | | |
| ៥៣.១.១០. រៀបចំ ដំឡើង និងអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងសារអេឡិចត្រូនិកនិងគេហទំព័រ កសហវ នៅក្នុងមជ្ឈមណ្ឌលទិន្នន័យរបស់ កសហវ | ឯកសារផែនការនិងតម្រូវការនៃការរៀបចំដំឡើងប្រព័ន្ធគ្រប់គ្រងសារអេឡិចត្រូនិកត្រូវបានរៀបចំរួចរាល់ | ផែនការនិងតម្រូវការ សម្រាប់ការរៀបចំដំឡើងប្រព័ន្ធគ្រប់គ្រងសារអេឡិចត្រូនិក ត្រូវបានកំណត់ជាបឋម | ៨០.០០% | រង់ចាំព័ត៌មានលម្អិតពាក់ព័ន្ធនឹងការកសាង Datacentre | |
| ៥៣.១.១១. ទំនើបកម្មប្រព័ន្ធចែករំលែកនិងរក្សាទុកឯកសារ សម្រាប់បង្កើនប្រសិទ្ធភាពការងារផ្ទៃក្នុងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ផែនការរៀបចំប្រព័ន្ធចែករំលែក និងរក្សាទុកឯកសារបានរៀបចំរួចរាល់ | មានឯកសារផែនការសម្រាប់រៀបចំប្រព័ន្ធចែករំលែក និងការរក្សាទុកឯកសារ | ១០០.០០% | | |
| ៥៣.១.១២. រៀបចំប្រព័ន្ធការិយាល័យវៃឆ្លាតដើម្បីចូលរួមបង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលជាផ្នែកមួយនៃ E-Government | មុខងារគ្រប់គ្រងការងារ មុខងារគ្រប់គ្រងវេទិការពិភាក្សា និងមុខងារគ្រប់គ្រងការកសាងសមត្ថភាព ត្រូវបានរៀបចំ និងកសាងរួចរាល់ដែលដំណើរការនៅលើ Web-Based Application និងផ្សព្វផ្សាយ អនុវត្ត | - ជិតបញ្ចប់ការកែសម្រួលលើមុខងារ ដែលកំពុងប្រើប្រាស់សាកល្បង<br>- បញ្ចប់ការសិក្សា និងកំពុងអភិវឌ្ឍ លើមុខគ្រប់គ្រងវេទិការពិភាក្សា និងមុខងារកសាងសមត្ថភាព<br>- បានកំពុងសិក្សាលើមុខងាររបាយការណ៍ ដែលជាតម្រូវការថ្មី | ៧៥.០០% | កង្វះខាតធនធានមនុស្សផ្នែកអភិវឌ្ឍកម្មវិធី ក្នុងការអភិវឌ្ឍកម្មវិធីប្រព័ន្ធព័ត៌មានវិទ្យាឱ្យបានសម្រេចតាមផែនការ | |
| ៥៣.១.១៣. សម្របសម្រួល និងគាំទ្រដល់ ការកសាងប្រព័ន្ធគ្រប់គ្រងសុវត្ថិភាពសម្រាប់ទីស្តីការ កសហវ | ផែនការកសាងប្រព័ន្ធគ្រប់គ្រងសុវត្ថិភាពនៅក្នុងកសហវ ត្រូវបានកែសម្រួលរួចរាល់ | -វិសាលភាពបន្ថែមនៃប្រព័ន្ធគ្រប់គ្រង សុវត្ថិភាពការចេញ-ចូល កសហវ ត្រូវបានកំណត់<br>-បានបញ្ចប់ការសិក្សាលើការបំពាក់ឧបករណ៍សម្រាប់ដំណាក់កាលដំបូង នៅរង់ចាំខាងក្រុមហ៊ុនផ្គត់ផ្គង់ ផ្តល់មកវិញនៅ ជម្រើសឧបករណ៍និងតម្លៃមកវិញ | ៩៥.០០% | ខាងក្រុមហ៊ុននៅមិនទាន់ផ្តល់មកវិញនៅជម្រើសឧបករណ៍និងតម្លៃសម្រាប់ដំណាក់កាលដំបូង | |

| | | | | | |
|---|---|---|---|---|---|
| ៥៣.១.១៤. សម្របសម្រួល និងគាំទ្រដល់ការកសាងប្រព័ន្ធគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ | ប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងចំណូលមិនមែនសារពើពន្ធត្រូវបានរៀបចំរួចរាល់សម្រាប់ថ្នាក់ជាតិ រួមជាមួយនឹងឯកសារសម្រាប់ការបណ្តុះបណ្តាល និងអាចអនុវត្តបាននៅតាមក្រសួងស្ថាប័នចំនួន ១៤ | ប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងចំណូលមិនមែនសារពើពន្ធត្រូវបានរៀបចំនិងដាក់ឱ្យអនុវត្តនៅក្រសួងស្ថាប័នចំនួន ១៤ រួមជាមួយនឹងការរៀបចំឯកសារសម្រាប់បណ្តុះបណ្តាល និង ការបណ្តុះបណ្តាលរួចរាល់ | ៩០.00% | តម្រូវការលម្អិតពីមុខងារក្នុងប្រព័ន្ធ លើផ្នែកខ្លះ នៅមិនទាន់បានសម្រេច ដែលទាមទារឱ្យមានការប្រជុំពិភាក្សាពីភាគីច្រើន | |
| ៥៣.១.១៥. រៀបចំ និងកសាងប្រព័ន្ធរបាយការណ៍វិភាគផ្នែកថវិកា និងហិរញ្ញវត្ថុសម្រាប់ថ្នាក់ដឹកនាំ កសហវ និងថ្នាក់ដឹកនាំនៃក្រសួងស្ថាប័ននានា | ប្រព័ន្ធរបាយការណ៍វិភាគផ្នែកថវិកា និងហិរញ្ញវត្ថុ (កញ្ចក់ថវិកា) បានរៀបចំរួចរាល់សម្រាប់ថ្នាក់ដឹកនាំ កសហវ និងដាក់ឱ្យដំណើរការជាផ្លូវការ | បានរៀបចំប្រព័ន្ធរបាយការណ៍វិភាគផ្នែកថវិកា និងហិរញ្ញវត្ថុ (កញ្ចក់ថវិកា) រួចរាល់ជំនាន់ទី១ និងបានដាក់បង្ហាញថ្នាក់ដឹកនាំពិនិត្យរួចរាល់ និងកំពុងកែលម្អលើចំណុចខ្វះខាតមួយចំនួនទៀតផងដែរ | ៩០.00% | | |
| ៥៣.១.១៦. សម្របសម្រួល និងគាំទ្រដល់ការកសាងប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងការងារលទ្ធកម្មសាធារណៈរបស់អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ (PPMIS) | -ឯកសារតម្រូវការត្រូវបានរៀបចំ និងបានបញ្ចប់ការកសាងមុខងារគ្រប់គ្រងវិជ្ជាការលើឯកសារដេញថ្លៃ<br>-រៀបចំរួចរាល់នូវឯកសារសម្រាប់ការបណ្តុះបណ្តាល | មុខងារគ្រប់គ្រងវិជ្ជាការលើឯកសារដេញថ្លៃ ត្រូវបានអភិវឌ្ឍជិតរួចរាល់ នៅសល់តែផ្នែកខ្លះដែលត្រូវកែសម្រួល និងត្រៀមដើម្បីបណ្តុះបណ្តាល | ៩៥.00% | | |
| ៥៣.១.១៧. សម្របសម្រួល និងគាំទ្រដល់ការកសាងប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងការងាររបស់អគ្គនាយកដ្ឋានគោលនយោបាយ | -គេហទំព័ររបស់អគ្គនាយកដ្ឋានគោលនយោបាយត្រូវបាន កសាងរួចរាល់ និងដាក់បង្ហោះជាផ្លូវការ<br>-ឯកសារតម្រូវការនៃការរៀបចំ និងកសាងប្រព័ន្ធគ្រប់គ្រងទិន្នន័យស្ថិតិសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវបានកំណត់ | - គេហទំព័ររបស់អគ្គនាយកដ្ឋានគោលនយោបាយត្រូវបានកសាងរួចរាល់ នៅរង់ចាំតែការសម្រេចពីថ្នាក់ដឹកនាំអគ្គនាយកដ្ឋានគោលនយោបាយដើម្បីដាក់ឱ្យប្រើប្រាស់ជាផ្លូវការ<br>- ឯកសារតម្រូវការនៃការរៀបចំ និងកសាងប្រព័ន្ធគ្រប់គ្រងទិន្នន័យស្ថិតិសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានរៀបចំរួចរាល់ | ១០០.00% | | |
| ៥៣.១.១៨. សម្របសម្រួល និងគាំទ្រដល់ការកសាងប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | បញ្ចប់ការប្រើប្រាស់សាកល្បងប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ កសហវ ដោយនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុនៃអគ្គលេខាធិការដ្ឋាន និងដាក់ឱ្យប្រើប្រាស់ជាផ្លូវការ | ប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ បានបញ្ចប់មុខងារគ្រប់គ្រងទៅលើបញ្ជីសារពើភ័ណ្ឌទាំង ៤ ប្រភេទ , ការ Upload តាម excel , កិច្ចសន្យា , តាមដានការជួសជុល , អ្នកប្រើប្រាស់ ,ការតាមដានការប្រើប្រាស់របស់អ្នកប្រើប្រាស់ និងទិន្នន័យបឋម | ៩៥.00% | | |
| ៥៣.១.១៩. សម្របសម្រួល និងគាំទ្រដល់ការកសាងកម្មវិធីគ្រប់គ្រងរបាយការណ៍ហិរញ្ញវត្ថុរបស់អង្គការ និងសហគមន៍នានា | -ឯកសារតម្រូវការមុខងារកម្មវិធីគ្រប់គ្រងរបាយការណ៍ហិរញ្ញវត្ថុរបស់អង្គការ និងសហគមន៍នានាបានរៀបចំរួចរាល់<br>-តម្រូវការ និងគ្រោងប្លង់បច្ចេកទេសនៃកម្មវិធីគ្រប់គ្រងរបាយការណ៍ហិរញ្ញវត្ថុរបស់អង្គការ និងសហគមន៍នានា បានរៀបចំរួចរាល់<br>-កម្មវិធីគ្រប់គ្រងរបាយការណ៍ហិរញ្ញវត្ថុរបស់អង្គការ និងសហគមន៍នានា បានរៀបចំរួចរាល់ ៧០% | -បានសិក្សា និងប្រមូលឯកសារតម្រូវការមុខងារកម្មវិធីគ្រប់គ្រងរបាយការណ៍ហិរញ្ញវត្ថុរបស់អង្គការ និងសហគមន៍នានា<br>-តម្រូវការ និងគ្រោងប្លង់បច្ចេកទេសនៃកម្មវិធីគ្រប់គ្រងរបាយការណ៍ហិរញ្ញវត្ថុរបស់អង្គការ និងសហគមន៍នានាត្រូវបានសិក្សា និងកំពុងរៀបចំ<br>-កម្មវិធីគ្រប់គ្រងរបាយការណ៍ហិរញ្ញវត្ថុរបស់អង្គការ និងសហគមន៍នានា បានរៀបចំរួចរាល់ប្រមាណជា ៦៨% | ៩០.00% | | |

**ខ. សេចក្តីសន្និដ្ឋាន**

នៅត្រីមាសទី១ ឆ្នាំ២០១៨ នេះ អគ្គលេខាធិការបានអនុវត្តផែនការសកម្មភាព GDAP3 2018 បានសម្រេច ១០០% មួយចំនួន និងសកម្មភាពមួយចំនួនទៀតមិនបានសម្រេចទាំងស្រុង ដោយផែនកសកម្មភាព នេះត្រូវបានកែតម្រូវ ជាច្រើនសារ ដើម្បីឱ្យផែនការសកម្មភាពនេះកាន់តែប្រសើរ និងស្របតាមបរិបទកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ទោះជាយ៉ាង ក៏លទ្ធផលសំខាន់មួយចំនួន សម្រេចបានភាគច្រើនជាង ៩០% ដោយសារ ថ្នាក់ដឹកនាំ និងមន្ត្រី នៃអគ្គលេខាធិការដ្ឋានបានខិតខំ ប្រតិបត្តិតាមផែនការសកម្មភាពនេះ។

ថ្ងៃច័ន្ទ ២រោច ខែចេត្រ ឆ្នាំ រកា នព្វស័ក ព.ស ២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែមេសា ឆ្នាំ ២០១៨

បានឃើញ និ ងឯកភាព
ថ្ងៃអង្គារ ៣រោច ខែចេត្រ ឆ្នាំ រកា នព្វស័ក ព.ស ២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែមេសា ឆ្នាំ ២០១៨
**ប្រធានក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**
**នៃអគ្គលេខាធិការដ្ឋាន**

**ហាស សុខសេនសាន**